រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ីកូ(ភ្នំពេញ) ខូអិលធីឌី

SHEICO(Phnom Penh)CO.,LTD

អាសយដ្ឋាន ផ្លូវជាតិលេខ៣ ភូមិ ស្រែញ័រ សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ

---

# **កិច្ចព្រមព្រៀង**
# **ស្តីពី**
# **ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត**
# **រវាង**

នាយករោងចក្រ និងសហជីព ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត

កម្មវត្ថុ៖ សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន៨៣នាក់រយៈពេលពីរខែ។

យោង៖ មាត្រា៧១ និងមាត្រា៧២ នៃច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីណែនាំស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស. សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីត-១៩ លេខៈ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។

ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង១៤និង៣០នាទី មានកិច្ចប្រជុំនៅរោងចក្រ ស៊ីកូ(ភ្នំពេញ)ខូអិលធីឌី បានព្រមព្រៀង និងឯកភាពគ្នាដូចខាងក្រោម៖

១- ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតផ្នែកដេរ ផ្នែកវេចខ្ចប់ ផ្នែកតុកាត់ ផ្នែកពិនិត្យ ផ្នែកបោះពុម្ព ផ្នែកឃ្លាំង សរុបចំនួន ៨៣នាក់ រយៈពេលពីរខែ ដោយគិតចាប់ពីថ្ងៃទី២៤ ខែមេសា រហូតដល់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។

២- នាយករោចក្រ និងសហជីព ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត បានព្រមព្រៀងផ្តល់ប្រាក់ចំនួន៣០ដុល្លាអាមេរិក ពីរោងចក្រ និងរាជរដ្ឋាភិបាលឧបត្ថម្ភ ៤០ដុល្លាអាមេរិក។

៣- ចូលធ្វើការវិញនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០។

កំណត់ហេតុនៃកិច្ចព្រមព្រៀងនេះ បានចប់សព្វគ្រប់នៅថ្ងៃដដែលវេលាម៉ោង១៥និង០០នាទី ក្រោមបរិយាកាសរីករាយ ឯកភាពគ្នា និងភាពស្និទ្ធស្នាលក្រៃលែង។

ភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០

ស្នាមមេដៃស្តាំសហជីព ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត

ហត្ថលេខា និងត្រាម្ចាស់ ឬនាយក

SHEICO (PHNOM PENH) CO.,LTD. HR
KINGDOM OF CAMBODIA